# ព្រះវិហារសសរឈើវត្តស្វាយសាច់ភ្នំ

វត្តស្វាយសាច់ភ្នំ ឬវត្តអម្ពវនារាម កសាងឡើងនៅប្រហែលប្រវត្តិមកក្រោយ ស្ថិតក្នុងឃុំស្វាយសាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ក្នុងបរិវេណវត្តនេះគេមើលឃើញមានសំណង់បុរាណជាច្រើន ជាពិសេសគឺព្រះវិហារចាស់មួយដ៏ល្បីល្បាញ ដែលមានសសរឈើធំៗទឹបមាស និងការតុបតែងលម្អផ្នែកផ្សេងៗនៃសំណង់ប្រកបដោយក្បាច់រចនាយ៉ាងល្អវិចិត្រក្រៃលែង។ នៅលើបល្ល័ង្កព្រះដីរ៍ លើសសរ លើជញ្ជាំង លើចំណងជើងគំនូរ និងលើខ្លោងទ្វារនៃព្រះវិហារនេះ តែងឃើញមានកត់ត្រាកាលបរិច្ឆេទផ្សេងៗគ្នាគួរឱ្យពិចារណា។ បើតាមការអះអាងរបស់អ្នកជំនាញ គិតមកដល់សព្វថ្ងៃព្រះវិហារវត្តស្វាយសាច់ភ្នំមានអាយុកាលប្រហែល១សតវត្សរ៍ ហើយបើតាមអ្នកស្រុកលើកឡើងថាកាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ព្រះវិហារខាងលើធ្លាប់ធ្វើជាឃ្លាំងដីអាចម៍គោក្របី។ ប៉ុន្តែយ៉ាងណាក្តី  ក្រោយប្រទេសមានសន្តិភាពឡើងវិញ ព្រះវិហារបុរាណនេះបានជួសជុលថែទាំបន្តបន្ទាប់ហូរហែមក ទុកសម្រាប់គោរពបូជាតំណាព្រះសាសនា (រូបលេខ១)។



*រូបលេខ១ ព្រះវិហារវត្តស្វាយសាច់ភ្នំក្រោយជួសជុលរួចជាស្ថាពរ (មើលពីជ្រុងពាយ័ព្យ)*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ផ្អែកតាមការសិក្សាផ្នែកសិល្បៈស្ថាបត្យកម្មសំណង់នៅតាមវត្តអារាម គេចាត់ព្រះវិហារវត្តស្វាយសាច់ភ្នំជាប្រភេទព្រះវិហារបុរាណ ឬព្រះវិហារជហ្វាបួនមួយបែប ដែលមានជញ្ជាំងជាប់សសរបាំងសាច(សសរជួរខាងក្រៅ) មានល្វែងខាងក្នុងព្រះវិហារស្រឡះ និងទូលាយសម្រាប់ធ្វើកិច្ចពិធីផ្សេងៗ។[1] តាមការសន្និដ្ឋានរបស់ Danielle និង Dominique-Pieree Guéret ព្រះវិហារនេះ គឺជាព្រះវិហារគំរូមួយក្នុងរាជ្យព្រះបាទពោត្តម។[2] បើពិនិត្យលើរូបថតកាលពីជាង១០ឆ្នាំមុន ព្រះវិហារបុរាណខាងលើសង់ឡើងនៅលើខឿនពីរថ្នាក់ ដែលមានខ្លោងទ្វារនៅតាមទិសនីមួយៗ។ ជញ្ជាំងព្រះវិហាររៀបឥដ្ឋ និងដំបូលប្រក់ក្បឿងស្រកាលេញ មានហប់ខ្យល់មុខក្រោយ ព្រមទាំងមានបំពាក់ជហ្វា២នៅចុងមេដំបូលខាងមុខ និងជហ្វា២ទៀតនៅចុងមេដំបូលខាងក្រោយ។ នៅតាមចុងចែងនីមួយៗ សុទ្ធតែលម្អដោយក្បាច់នាគដងក្តារ ដែលជាប្រភេទក្បាច់ពុម្ពស៊ីម៉ងត៍។ រីឯការប្រើពណ៌លាបលម្អ គេសង្កេតឃើញជាពណ៌មិនឆើតឆាយឡើយ ពោលគឺជហ្វាទាំងបួនលាបពណ៌សផ្ទៃហោជាងលាបពណ៌លឿងស្រាល តែនាគដងក្តារ និងរងស្បូវពុំលាបពណ៌ទេ។ ផ្ទៃជញ្ជាំង គេលាបពណ៌ស រំលេចលម្អដោយក្បាច់សសរតាមជញ្ជាំង និងស៊ុមទ្វារ-បង្អួចពណ៌ប្រផេះ។ លើសពីនេះ អ្វីគួរឱ្យកត់សម្គាល់ គឺនៅចុងដំបូលផ្នែកខាងមុខនិងខាងក្រោយពុំមានតសំយ៉ាបគ្រប់ជណ្តើរដូចឃើញសព្វថ្ងៃឡើយ (រូបលេខ២)។ ប៉ុន្តែយ៉ាងណាក្តី ក្រោយការជួសជុលចុងក្រោយរបស់អ្នកជំនាញក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (បញ្ចប់នៅក្នុងចុងឆ្នាំ២០១៧) គេសង្កេតឃើញព្រះវិហារវត្តស្វាយសាច់ភ្នំនៅរក្សារចនាសម្ព័ន្ធទូទៅ និងការលាបពណ៌លម្អស្មើរដូចលំនាំដើមដដែល។



**រូបលេខ២ រូបភាពព្រះវិហារវត្តស្វាយសាច់ភ្នំមុនជួសជុល (រូបថត៖ ព្រាប ចាន់ម៉ារ៉ា, ២០០៩-២០១០, យសោធរ)**

[1] ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-១៦

[2] *Danielle & Dominique-Pieree Guéret 2017; 108*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ដោយឡែកចំពោះការលម្អលើហោជាងដែលឃើញសព្វថ្ងៃនៅលើព្រះវិហារនេះ ហាក់ប្លែកពីព្រះវិហារផ្សេងៗ ដ្បិតសិល្បករជ្រើសរើសប្រើក្បាច់ភ្ញីភ្ញើងមករចនាលម្អលើហោជាងទាំងមុខ និងក្រោយៗ[3] ក្បាច់ភ្ញីភ្ញើងលម្អនោះសោត ធ្លាក់ពីស៊ីម៉ងត៍ស្តើងៗចេញពីគល់ហោជាង រលាស់ឡើងទៅលើ ព័ទ្ធជុំវិញរូបព្រះវិស្ណុ(?) គង់លើបល្ល័ង្កទាបមួយដែលនៅក្នុងព្រះហត្ថទាំងពីរកាន់អាវុធជាកេតនភណ្ឌ (រូបលេខ៣-៤)។ បើមើលក្នុងរូបថតឯកសារផ្សេងៗមុនជួសជុល ហោជាងព្រះវិហារនេះលាបផ្ទៃពណ៌លឿងស្រាល ក្រោយមកលាបពណ៌ផ្កាឈូក ហើយសន្ទឹកក្បាច់នីមួយៗរំលេចដោយពណ៌ទឹកមាស។



រូបលេខ៣-៤ ក្បាច់លម្អនៅលើហោជាងខាងកើត និងហោជាងខាងលិចនៃព្រះវិហារវត្តស្វាយសាច់ភ្នំ

ចំណែកឯការលម្អលើជញ្ជាំងខាងក្រៅព្រះវិហារ គេឃើញមានផ្នែកខ្លះគួរឱ្យចាប់កត់សម្គាល់ដែរ។ ផ្ទៃជញ្ជាំងសព្វថ្ងៃគេលាបពណ៌ស ក្បាច់លម្អសសរនីមួយៗលាបពណ៌ប្រផេះ តែអ្វីដែលពិសេសគឺនៅតាមគល់សសរមានធ្លាក់រូបផ្សេងៗ ទំនងជាតួអង្គដកស្រង់ចេញពីរឿងរាមកេរ្តិ៍ ឬរឿងបុរាណណាមួយ ហើយនៅផ្នែកខាងលើរូបទាំងនោះគេតែងសង្កេតឃើញចារពាក្យមួយឃ្លាខ្លីថា "ព្រះសាស្នាបាន២៤៦៨" ត្រូវនឹងឆ្នាំ១៩២៥ (រូបលេខ៥-៧)។ លើសពីនេះបើមើលទៅដល់ខ្លោងទ្វារទាំងបួនទិសជុំវិញព្រះវិហារ តែងឃើញមានចំណារឈ្មោះអ្នកមានសទ្ធាកសាង និងកាលបរិច្ឆេទបញ្ជាក់ឆ្នាំ១៩២៨។

[3] បើផ្អែកតាមឯកសារក្បាច់ខ្មែរ ក្បាច់ភ្ញីភ្ញើងច្រើនតែប្រើលម្អលើសំណង់ក្នុងពិធីផ្សេងៗដូចជា បុណ្យសព បុណ្យសំពះគ្រូ បុណ្យអភិសេក និងឧបករណ៍ផ្សេងៗដែលទាក់ទងនឹងគ្រឿងចម្បាំង ផ្នែកអគ្គីភ័យ និងកីឡាជាដើម (ច័ន្ទ វិត្ថារិទ្ធ ២០០៥: ៣២៨)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៩-៧ ចម្លាក់រូបផ្សេងៗនៅតាមគល់សសរលើជញ្ជាំងខាងក្រៅ

របនាសម្ព័ន្ធផ្នែកខាងក្នុងព្រះវិហារ គេសាងឡើងចែកជា៥ល្វែង ដោយមានសសរឈើធំៗបួនជួររចនាលម្អដោយក្បាច់ និងគំនូរទឹកមាសយ៉ាងល្អឯក អមសងខាងល្វែងគ្រឹះ (រូបលេខ៨)។ ប៉ុន្តែព្រះវិហារនេះ គេរៀបជញ្ជាំងឥដ្ឋបូកកំបោរបាយអរនៅជាប់សសរបាំងសាច ដែលធ្វើឱ្យខាងក្នុងព្រះវិហារកាន់តែស្រឡះ និងធំទូលាយ។ នៅខាងចុងខាងលិចនៃល្វែងគ្រឹះ គឺជាបល្ល័ង្កតម្កល់ព្រះជីវ៍ធំដែលសាងមកក្រោយសម័យសង្គ្រាម (រូបលេខ៩)។ បើយោងតាមចារឹកពីរផ្ទាំងដែលចារជាប់នៅផ្នែកខាងក្រោយបល្ល័ង្កឱ្យដឹងថា ព្រះវិហារវត្តស្វាយសាច់ភ្នំនេះកសាងឡើងក្នុងព្រះពុទ្ធសករាជ២៤៤៨ (ឆ្នាំ១៩០៥) ហើយសាងបល្ល័ង្ក និងព្រះជីវ៍ក្នុងព្រះពុទ្ធសករាជ២៥២៥ (ឆ្នាំ១៩៨២)។ អ្វីគួរឱ្យកត់សម្គាល់ គឺនៅផ្នែកខាងមុខនៃបល្ល័ង្កព្រះជីវ៍គេឆ្លាក់រូបព្រះពុទ្ធបរិនិព្វាន ដែលកម្រឃើញនៅតាមបណ្តាព្រះវិហារផ្សេងៗ ប៉ុន្តែកាយវិការនៃព្រះបដិមាព្រះជីវ៍ គឺសាងឡើងក្នុងទម្រង់ជាព្រះពុទ្ធម្នាញ់មារ ដោយទ្រង់គង់ព្រះភ្នែន ព្រះបាទស្តាំគងលើព្រះបាទឆ្វេង ព្រះហស្តស្តាំលាសំយុងចុងម្រាមទៅក្រោម ហើយព្រះហស្តឆ្វេងលាផ្ងារដាក់លើចុងព្រះបាទស្តាំ ដូចការនិយមតាមវត្តនានាដែរ។ ចំណែកឯនៅខាងក្រោយបល្ល័ង្ក គេឆ្លាក់រូបនាងគង្ហីងព្រះធរណីច្របួតសក់ បង្ហាញឱ្យឃើញជាក់ស្តែងដូចក្នុងរឿងពុទ្ធប្រវត្តិត្រង់ឈុតព្រះពុទ្ធអង្គទ្រង់ផ្ចាញ់មារ។[4]

4 ព្រាប ចាន់ម៉ារ៉ា ២០១៥: ២៤-៣០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៨ ផ្នែកខាងក្នុងព្រះវិហារ



រូបលេខ៩ ព្រះដីវ៍សាងថ្មីក្រោយសង្គ្រាម

ចំពោះការរចនាក្បាច់លម្អ និងគំនូរទឹបមាសលើសសរព្រះវិហារវិញ គេសម្គាល់ឃើញប្លែកពីព្រះវិហារដទៃ ដ្បិតសសរខ្លះមានរំលេចជារូបរុក្ខជាតិតូចៗ មានវល្លិ មានដើម ទង ស្លឹក ផ្កា ផ្លែ និងតួអង្គក្នុងរឿងបុរាណដូចជា កិន្នរ យក្ស នាគ ឬរូបតួអង្គទេព ឬសត្វផ្សេងៗក្នុងរឿងទេពកថាជាដើម (រូបលេខ១០)។ សូមបញ្ជាក់ថាសសរទាំងបួនជួរក្នុងព្រះវិហារនេះមានសរុប៣២ដើម ធ្វើពីឈើឈូសឱ្យមូលរលោង ទំហំមួយឱបមនុស្ស ទ្រគ្រឿងបង្គុំឈើផ្នែកខាងលើ (រូបលេខ១១)។ ប៉ុន្តែក្នុងចំណោមសសរទាំងអស់មានសសរមួយដើមនៃជួរខាងស្តាំក្បែរបល្ល័ង្កព្រះដីវ៍ គឺជាសសរបេតុង ធ្វើថ្មីតាមទំហំ និងលំនាំសសរឈើដែលពុកខូចទៅ ហើយក្នុងចំណោមសសរទាំង៣២ដើមនោះដែរ មានសសរមួយទៀតចារឹកកាលបរិច្ឆេទខ្ញីថា "ព្រះសាស្នាបាន២៤៥៤" (ឆ្នាំ១៩១១)។





រូបលេខ១០-១១ ការរចនាក្បាច់និងគំនូរទឹបមាសលើសសរនីមួយៗ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

គំនូរខាងក្នុងព្រះវិហារ គូរនៅលើផ្នែកសំខាន់ៗនៃសំណង់ដូចជា ពិតាន ហប់ខ្យល់ និងលើជញ្ជាំងជុំវិញ។ ប្រធានបទដែលលើកមកគូរក្នុងព្រះវិហារនេះ គឺឈុតសំខាន់ៗនៃរឿងពុទ្ធប្រវត្តិ រឿងជាតក គំនូរព្រះអាទិត្យ និងព្រះចន្ទ្រ ដូចបណ្តាព្រះវិហារផ្សេងដែរ។ ប៉ុន្តែបើគេពិនិត្យឱ្យល្អិត គេមើលឃើញថាគំនូរលើហប់ខ្យល់មុខក្រោយ គឺជាគំនូរបុរាណដែលទំនងគូរតាំងពីចាប់ផ្តើមកសាងព្រះវិហារ។ ចំណែកឯគំនូរលើជញ្ជាំងជុំវិញមួយភាគធំ មានចុះកាលបរិច្ឆេទគូរក្នុងឆ្នាំ១៩៥៦-១៩៥៧ ដោយវិចិត្រករឈ្មោះ ណៃម និង ម៉ក់។ ដោយឡែក គំនូរមួយផ្នែកទៀតនៃជញ្ជាំងជុំវិញនោះដែរ រួមទាំងគំនូរលើពិតាន គឺជាគំនូរថ្មី គូរឡើងវិញបន្ទាប់ពីជួសជុលព្រះវិហារ ក្រោយចប់សង្គ្រាម ពោលគឺគូរបំពេញសាច់រឿងដែលខូចខាតកាលសម័យសង្គ្រាម (រូបលេខ១២-១៥)។



រូបលេខ១២ គំនូរថ្មីលើពិតាន និងគំនូរបុរាណលើហប់ខ្យល់



រូបលេខ១៣ គំនូរថ្មីគូរលើជញ្ជាំងខាងកើត





រូបលេខ១៤-១៥ គំនូរចាស់គូរក្នុងឆ្នាំ១៩៥៧ នៅលើជញ្ជាំងខាងជើង

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*ជាសង្ខេបមក បើផ្អែកតាមកាលបរិច្ឆេទចារលើផ្នែកផ្សេងៗនៃសំណង់ដូចរៀបរាប់ខាងលើ នាំឱ្យយើងកាត់យល់បានថា ព្រះវិហារវត្តស្វាយសាច់ភ្នំទំនងចាប់ផ្ដើមសាងសង់ក្នុងព.ស.២៤៤៨ (ឆ្នាំ១៩០៥) រចនាក្បាច់និងគូរគំនូរទឹកមាសលើសសរក្នុងព.ស.២៤៥៤ (ឆ្នាំ១៩១១)។ បន្ទាប់មក ទើបរៀបជញ្ជាំងឥដ្ឋបូកកំបោរបាយអរដូចឃើញសព្វថ្ងៃនៅក្នុងព.ស.២៤៦៨ (ឆ្នាំ១៩២៥) និងសាងខ្លោងទ្វារជុំវិញក្នុងព.ស.២៤៧១ (ឆ្នាំ១៩២៨ )។[5] លុះចូលដល់រវាងព.ស.២៤៩៩-២៥០០ (ឆ្នាំ១៩៥៦-១៩៥៧ ) ទើបគូរគំនូរលើជញ្ជាំងខាងក្នុងព្រះវិហារ ហើយក្រោយសង្គ្រាមបញ្ចប់ ទើបគេកសាងបល្ល័ង្កនិងព្រះដីវ៍ថ្មីឡើងវិញក្នុងព.ស.២៥២៥ (ឆ្នាំ១៩៨២) ដូចឃើញសព្វថ្ងៃ។[6]*

## ឯកសារយោង


*ច័ន្ទ វិត្ថារិទ្ធ*

២០០៥, *ក្បាច់ខ្មែរ*, រៃយំ, ភ្នំពេញ

*ព្រាប ចាន់ម៉ារ៉ា*

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

២០១៥, "ផ្ចាញ់មារ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១០, ទំ.២៤-៣០, យសោធរ, ភ្នំពេញ

*Danielle & Dominique-Pieree Guéret*

2017, *The Khmer Pagoda*, KAM edition


[5] *អ្នកខ្លះសន្និដ្ឋានថា ដើមឡើយប្រហែលជញ្ជាំងព្រះវិហារនេះជាជញ្ជាំងឈើ។*

[6] *Danielle & Dominique-Pieree Guéret 2017; 108*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*